00693902

លេខ / No: D14

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស.**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ចំពោះមុខ ៖ **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម Siegfried BLUNK**

កាលបរិច្ឆេទ ៖ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១

ភាសា ៖ អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ ៖ សាធារណៈ

**ដីកាសម្រេចស្តីអំពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញា**
**អន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 18 / 05 / 2011
ម៉ោង (Time/Heure): 11:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស. លេខ/No: D14

យើង យូ ប៊ុនឡេង និង Siegfried BLUNK (ស៊ីគហ្វ្រីដ ប៊្លុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក.”)

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ (“ច្បាប់ស្តីពី អ.វ.ត.ក”)

បានឃើញវិធាន ២១ វិធាន ៥៤ វិធាន ៥៥ វិធាន ៥៦ និង វិធាន ៦៦ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក (វិសោធនកម្មលើកទី ៧) (“វិធានផ្ទៃក្នុង”)

បានឃើញការស៊ើបសួរ ដែលកំពុងដំណើរការស្របតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា

បានឃើញសេចក្តីជូនដំណឹងស្តីអំពីការបិទការស៊ើបសួរ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ (D13)

បានឃើញសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១ (“សេចក្តីប្រកាសព័ត៌មាន”) ដែលផ្សព្វផ្សាយនៅលើគេហទំព័រ អ.វ.ត.ក ។

## I. ការរំលឹកឡើងវិញអំពីនីតិវិធី

១. ជាមួយនឹងព័ត៌មានផ្សេងៗទៀត សេចក្តីប្រកាសព័ត៌មានបានបង្ហាញនូវព័ត៌មាន ដូចជា៖ (ក) ព័ត៌មានទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលសហព្រះរាជអាជ្ញាអន្តរជាតិយល់ថាតម្រូវឱ្យមានការស៊ើបសួរ។ ការណ៍ធ្វើដូច្នេះ មានន័យថាជាការបង្ហាញយ៉ាងលម្អិតនូវផ្នែកនៃសំណុំរឿង ០០៣ ដែលមានដូចជា ឧក្រិដ្ឋកម្មដែលចោទប្រកាន់ ទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ឧក្រិដ្ឋកម្ម ។ (ខ) ខ្លឹមសារនៃសំណើសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម ដែលអនុលោមតាមវិធាន ៦៦.១ ។

00693904



២. ពាក់ព័ន្ធនឹងព័ត៌មានប្រភេទ (ក) សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា *"ឧក្រិដ្ឋកម្មនានាតម្រូវឱ្យធ្វើស៊ើបសួរជាផ្នែកនៃសំណុំរឿង ០០៣ បានកើតឡើងនៅតាមទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ឧក្រិដ្ឋនានាជាច្រើនដែលគ្របដណ្តប់ដោយសំណុំរឿងលេខ ០០២ ដែលរួមមាន៖ មន្ទីរសន្តិសុខ ស-២១ ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការបោសសម្អាតភូមិភាគបូព៌ា ភូមិភាគកណ្តាល និងភូមិភាគឧត្តរថ្មី ហើយនិងការលុកលុយចូលក្នុងប្រទេសវៀតណាម ក៏ដូចជាទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មថ្មីៗនានា ដូចខាងក្រោមនេះ៖ (១) មន្ទីរសន្តិសុខ ស-២២ នៅក្នុងតំបន់ភ្នំពេញ ។ (២) មន្ទីរសន្តិសុខវត្តអង្គតាញាណនៅក្នុងខេត្តកំពង់សោម ។ (៣) ការដ្ឋានពលកម្មដោយបង្ខំកន្លែងយកថ្មនៅស្ទឹងហាវនៅក្នុងខេត្តកំពង់សោម ។ (៤) ការចាប់ចង ជនជាតិបរទេសនៅក្បែរតំបន់ឆ្នេរសមុទ្រកម្ពុជា និងការដាក់ពួកគេនៅក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ ការបញ្ជូនទៅ ស-២១ ឬការសម្លាប់ ។ និង (៥) មន្ទីរសន្តិសុខនានាដែលបានដំណើរការប្រព្រឹត្តទៅនៅក្នុងខេត្តរតនៈគីរី" ។*

៣. ពាក់ព័ន្ធនឹងព័ត៌មានប្រភេទ (ខ) សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការបង្ហាញជាសាធារណៈនូវសំណើសុំឱ្យមានកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៦៦.១ នៃវិធានផ្ទៃក្នុង ដោយបានលើកឡើងថា៖

*"ដោយបានពិនិត្យឡើងវិញលើសំណុំរឿងយ៉ាងហ្មត់ចត់ សហព្រះរាជអាជ្ញាអន្តរជាតិមានបំណងស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមទៀតពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនានាដែលបានលើកឡើងចោទប្រកាន់ក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ ដូចដែលបានកំណត់នៅក្នុងវិធាន ៦៦.១ នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក ។ ក្នុងចំណោមអ្វីៗផ្សេងទៀតជាច្រើន សហព្រះរាជអាជ្ញាអន្តរជាតិនឹងស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត៖*

*១. កោះហៅ និងសួរចម្លើយជនសង្ស័យនានាដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើសំណុំរឿងលេខ ០០៣ និងកំណត់អត្តសញ្ញាណអ្នកទាំងនោះថាពួកគេស្ថិតនៅក្រោមការស៊ើបសួរ ។*

*២. ស្តាប់ចម្លើយបុគ្គលបន្ថែមថ្មីដែលរហូតមកដល់ពេលនេះត្រូវបានកំណត់អត្តសញ្ញាណថាជាសាក្សីដែលមានសក្តានុពល ។*

*៣. ស្តាប់ចម្លើយ ឬស្តាប់ចម្លើយសារជាថ្មីឡើងវិញ ចំពោះសាក្សីនានាដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងសំណុំរឿងលេខ ០០២ ដោយផ្តោតទៅលើការលើកឡើងចោទប្រកាន់ជាក់លាក់នានាដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើសំណុំរឿងលេខ ០០៣ ។*

00693905



*៤. ពិនិត្យបន្ថែមទៀតទៅលើទីតាំងឧក្រិដ្ឋកម្មនានា (រួមទាំងការស្រាវជ្រាវរកទីកន្លែងកប់សាកសពរួម)។*

*៥. ដាក់ភស្តុតាងបន្ថែមចូលទៅក្នុងសំណុំរឿង រួមទាំងការផ្ទេរភស្តុតាងបន្ថែមទៀតពីសំណុំរឿងលេខ ០០២ ទៅក្នុងសំណុំរឿងលេខ ០០៣ ។ និង*

*៦.ស៊ើបសួរបន្ថែមទៀតអំពីការចូលរួមរបស់ជនសង្ស័យនៅក្នុងសំណុំរឿងលេខ ០០៣ នៅក្នុងឧក្រិដ្ឋកម្មនានា រួមទាំងការបញ្ជូនពួកអ្នកទោសដែលស្ថិតនៅក្រោមការត្រួតត្រារបស់ពួកគេឱ្យទៅកាន់មន្ទីរ ស-២១ ការទទួលបានរបស់ជនសង្ស័យនូវ "ចម្លើយសារភាព" ដែលស្រង់បានពីពួកអ្នកជាប់គុកដែលត្រូវបានគេសម្លាប់នៅមន្ទីរ ស-២១ និងការចូលរួមរបស់ពួកគេនៅក្នុងការចាប់ខ្លួនបន្តបន្ទាប់មកទៀត" ។*

## II. សំអាងហេតុនៃសេចក្ដីសម្រេច

**<u>ព័ត៌មានប្រភេទ "ក" នៃសេចក្ដីប្រកាសព័ត៌មាន</u>**

៤. វិធាន ៥៤ នៃវិធានផ្ទៃក្នុងចែងថា៖ *"ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដីកាសន្និដ្ឋានស្ដាពរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា គឺជាឯកសារសម្ងាត់។ ប៉ុន្តែដោយគិតដល់តម្រូវការក្នុងការផ្ដល់ព័ត៌មានដល់សាធារណៈជនអំពីវិឌ្ឍនភាពនៃដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ សហព្រះរាជអាជ្ញាអាចផ្ដល់ឱ្យសាធារណៈជននូវព័ត៌មានសង្ខេបដែលមាននៅក្នុងដីកាទាំងនេះ ដោយគិតពិចារណាដល់សិទ្ធិក្នុងការការពារខ្លួន ផលប្រយោជន៍របស់ជនរងគ្រោះ សាក្សី និងជនដទៃទៀតដែលមានឈ្មោះក្នុងដីកានោះ និងតម្រូវការផ្នែកស៊ើបអង្កេត"*

អនុលោមតាមវិធាននេះ សហព្រះរាជអាជ្ញាអន្តរជាតិមានសិទ្ធិត្រឹមតែផ្ដល់នូវការសង្ខេបនៃការដាក់ដីកាបញ្ជូនរឿងឱ្យស៊ើបសួរក្នុងសំណុំរឿង ០០៣ តែប៉ុណ្ណោះ ដោយពុំមានសិទ្ធិធ្វើការបង្ហាញមតិយោបល់ជាសាធារណៈទាក់ទងនឹង "ឧក្រិដ្ឋកម្មដែលតម្រូវឱ្យមានការស៊ើបសួរ" នោះឡើយ ព្រោះនេះជា កិច្ចការ ស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត (វិធាន ៥៥.១) ។

៥. វិធាន ៥៤ មានចែងបន្ថែមទៀតថា៖ *"លើសពីនេះទៅទៀត សហព្រះរាជអាជ្ញាអាចកែតម្រូវរួមគ្នាដោយផ្ទាល់ ឬ តាមរយៈផ្នែកកិច្ចការសាធារណៈនូវព័ត៌មានមិនពិត ឬព័ត៌មាននាំឱ្យមានការភ័ន្តច្រឡំនៅពេលដែលសំណុំរឿងនោះ ស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេតបឋម"* ។

ទោះបីជាយ៉ាងនេះក៏ដោយ ការស៊ើបអង្កេតបឋម (វិធាន ៥០) បានបញ្ចប់ជាមួយនឹងការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមកសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន ៥៣.១ នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ រួចទៅហើយ។

៦. ជារួម សហព្រះរាជអាជ្ញាអន្តរជាតិមិនមានមូលដ្ឋានផ្លូវច្បាប់ណាមួយ ក្នុងការបង្ហាញនូវព័ត៌មានប្រភេទ "ក" នៃសេចក្តីប្រកាសព័ត៌មាន នោះឡើយ ។

**<u>ព័ត៌មានប្រភេទ "ខ" នៃសេចក្តីប្រកាសព័ត៌មាន</u>**

៧. វិធាន ៥៦ ចែងថា៖ *"ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ។ បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួរត្រូវរក្សាឲ្យបាននូវការសម្ងាត់"*

ទោះបីជាយ៉ាងនេះក៏ដោយ សហព្រះរាជអាជ្ញាបានរំលោភលើវិធាននៃការរក្សាការសម្ងាត់ ដោយបានជូនដំណឹងដល់សាធារណជន ជាមុន និងយ៉ាងលម្អិតអំពីការណ៍ដែលខ្លួន *"ស្នើសុំដល់សហចៅក្រមស៊ើបអង្កេតឲ្យ"* អនុលោមតាមវិធាន ៦៦.១ នៃវិធានផ្ទៃក្នុង ។

៨. ដោយយោងទៅលើអនីត្យានុកូលភាពនៃព័ត៌មានប្រភេទ "ក" និងការរំលោភលើវិធាននៃការរក្សាការសម្ងាត់ទាក់ទងនឹងព័ត៌មានប្រភេទ "ខ" សហព្រះរាជអាជ្ញាអន្តរជាតិត្រូវធ្វើការផ្សព្វផ្សាយអំពីការដកសេចក្តីប្រកាសព័ត៌មានដែលបានធ្វើ នៅក្នុងទំរង់ដូចដែលខ្លួនបានចេញសេចក្តីប្រកាសព័ត៌មាននេះ ។ ការណ៍នេះធ្វើឡើងដើម្បីធ្វើឲ្យមានទំនុកចិត្តឡើងវិញនៅក្នុងនីត្យានុកូលភាព និងការសម្ងាត់នៃការស៊ើបសួរ និងត្រូវធ្វើឡើងក្នុងរយៈពេលដ៏ខ្លីខាងមុខ ។

III. **សេចក្តីសម្រេច**

**៩.** អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតសម្រេចបង្គាប់ឲ្យសហព្រះរាជអាជ្ញាអន្តរជាតិធ្វើការផ្សព្វផ្សាយអំពីការដកចេញពីសេចក្តីប្រកាសព័ត៌មាននូវព័ត៌មានប្រភេទ "ក" និង "ខ" ដែល

00693907

០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស. លេខ/No: D14

បានផ្សព្វផ្សាយនៅលើគេហទំព័រ អ.វ.ត.ក ក្នុងរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃនៃការដាក់ឯកសារ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១

សហចៅក្រមស៊ើបអង្កេត

Co-Investigating Judges

Co-juges d'instruction

*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

យូ ប៊ុនឡេង

Dr. Siegfried BLUNK